RAC Ratings

របាយការណ៍ត្រួតពិនិត្យការវាយតម្លៃលទ្ធភាពសង
លេខ៖ ០១២/២៦
ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦

ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ម.ក

ចំណាត់ថ្នាក់ឥណទាន		ព័ត៌មានសញ្ញាបណ្ណទី១		ព័ត៌មានសញ្ញាបណ្ណទី២	
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khCCC**	ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**	ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**
ទស្សនវិស័យ	**អវិជ្ជមាន**	ទំហំ	**១២ លានដុល្លារអាមេរិក**	ទំហំ	**១២ លានដុល្លារអាមេរិក**
ប្រវត្តិនៃការវាយតម្លៃលទ្ធភាពសង		ចំនួននៃការទូទាត់	**ការប្រាក់៖ ប្រចាំឆមាស ប្រាក់ដើម៖ រំលស់ពីឆ្នាំទី៣ ដល់ទី៥**	ចំនួននៃការទូទាត់	**ការប្រាក់៖ប្រចាំឆមាស ប្រាក់ដើម៖ រំលស់ពីឆ្នាំទី៣ ដល់ទី១០**
ចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន	**khCCC**	រយៈពេលឥណប្រតិទាន	**ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៧**	រយៈពេលឥណប្រតិទាន	**ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០៣២**
ទស្សនវិស័យ	**អវិជ្ជមាន**	ប្រភេទ	**មិនមានទ្រព្យតម្កល់ ប៉ុន្តែមានបុគ្គលជានា**	ប្រភេទ	**មិនមានទ្រព្យតម្កល់ ប៉ុន្តែមានបុគ្គលជានា**
ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ	**khAAA**	អត្រាគូប៉ុង	**SOFR+៣,៥% ក្នុងមួយឆ្នាំ**	អត្រាគូប៉ុង	**ឆ្នាំទី១ដល់ឆ្នាំទី៥៖ SOFR+៣,៥% ក្នុងមួយឆ្នាំ ឆ្នាំទី៦ដល់ឆ្នាំទី១០៖ SOFR+៣,៧៥% ក្នុងមួយឆ្នាំ**
កាលបរិច្ឆេទបោះផ្សាយ	**ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤**	បុគ្គលជានា	**GuarantCo**	បុគ្គលជានា	**GuarantCo**

អ្នកវាយតម្លៃ៖

លោកស្រី កាឡូ សូរីតា
k.sorita@ratingagency.com.kh
(+៨៥៥) ១៧ ៣៩២ ៧៧៧

លោក ពេជ្រ ម៉េងហ៊ុយ
p.menghuy@ratingagency.com.kh
(+៨៥៥) ១៧ ២៥០ ៧៧៧

លោក ដូ ដេវីត
z.david@ratingagency.com.kh
(+៨៥៥) ១៧ ៧៧៧ ៦៤៣

លោក ពឹង ធៀមហេង
p.theamheng@ratingagency.com.kh
(+៨៥៥) ១៧ ៧៧៧ ១៧៨

កញ្ញា រិន មន្នីរ័ត្ន
r.monyroth@ratingagency.com.kh
(+៨៥៥) ១៧ ៧៧៧ ៤០៦

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ

យើងរក្សាចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណរបស់ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវេ ម.ក («RR» ឬ «ក្រុមហ៊ុន») នៅ «**khAAA**» (ចំណាត់ថ្នាក់ជាតិ)។ សញ្ញាបណ្ណនេះមានការធានា១០០% ទៅលើទាំងប្រាក់ដើមនិងការប្រាក់ដោយ GuarantCo ជាស្ថាប័នដែលបច្ចុប្បន្ននេះទទួលបានចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន AA- ពី Fitch Ratings និង A1 ពី Moody's Investor Service។

យើងក៏រក្សាចំណាត់ថ្នាក់ឥណទានក្រុមហ៊ុននិងទស្សនវិស័យរបស់ RR នៅ «**khCCC**» (ចំណាត់ថ្នាក់ជាតិ) និង «**អវិជ្ជមាន**» ផងដែរ។ លទ្ធផលចុងក្រោយក្នុងឆ្នាំ២០២៥ បានបង្ហាញពីភាពរីកចម្រើននៃប្រតិបត្តិការ ប៉ុន្តែការកើនឡើងចំណាយការប្រាក់បានបន្តដាក់សម្ពាធទៅលើប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ការកើនឡើងតម្លៃប្រេងម៉ាស៊ូតក៏បានបន្ថែមសម្ពាធទៅលើប្រាក់ចំណេញផងដែរ។ កត្តាទាំងនេះបាននាំឱ្យ RR បំពានលើកិច្ចព្រមព្រៀងឥណទាន និងជំរុញឱ្យមានការដាក់លិខិតស្នើសុំការលើកលែងទៅ GuarantCo។ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ត្រួតពិនិត្យការវាយតម្លៃលទ្ធភាពសងនេះ ក្រុមហ៊ុនបានទទួលការលើកលែងក្រោមលិខិតធានាសងវិញ (Recourse Deed) គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ និងបានដាក់លិខិតស្នើសុំការលើកលែងមួយផ្សេងទៀតចំពោះការបំពានកិច្ចសន្យា គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។

បើប្រៀបធៀបជាមួយឆ្នាំមុន ប្រាក់ចំណូលរបស់ក្រុមហ៊ុន ប្រាក់ចំណេញពីប្រតិបត្តិការ និងលំហូរសាច់ប្រាក់ពីប្រតិបត្តិការ មានការប្រសើរឡើងបើទោះបីជាតួលេខទាំងនោះនៅតែមានសភាពអវិជ្ជមាន។ ប្រាក់ខាតសុទ្ធប្រចាំឆ្នាំត្រូវបានកាត់បន្ថយ ដោយសារចំណាយការប្រាក់មានកម្រិតទាបជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ចំណាយ

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.

អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

ហេតុផលសំខាន់ៗនៅក្រោយការវាយតម្លៃ (ត)

ការប្រាក់ខ្ពស់ និងតម្លៃប្រេងម៉ាស៊ូត នៅតែជាកត្តិបារម្ភចំពោះលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងកំឡុងពេលដែលសញ្ញាបណ្ណមានសុពលភាព។

យើងរក្សាទស្សនវិស័យនេះក្នុងរយៈពេលមធ្យម ដោយយើងជឿជាក់ថា កត្តាចម្បងដែលប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាពោលគឺ អត្រាការប្រាក់ឡើងខ្ពស់ តម្លៃប្រេងម៉ាស៊ូតកើនឡើង និងភាពមិនច្បាស់លាស់នៃភូមិសាស្ត្រនយោបាយ នឹងកាត់បន្ថយនាពេលអនាគតដ៏ខ្លី។ យ៉ាងណាក៏ដោយ យើងនៅតែរក្សាការប្រុងប្រយ័ត្នចំពោះសក្តានុពលនៃការធ្លាក់ចុះសេដ្ឋកិច្ចដែលអាចជំរុញឱ្យមានការត្រួតពិនិត្យឡើងវិញនៃការវាយតម្លៃ ដោយឃើញថា RR រងឥទ្ធិពលខ្លាំងពីវដ្តសេដ្ឋកិច្ចសកលលោក តំបន់ និងក្នុងស្រុក។

ទស្សនវិស័យ

ចំណូលមកពីការដឹកជញ្ជូនទំនិញ និងសេវាកម្មតម្លៃបន្ថែមពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមរថភ្លើង ជាពិសេសពីខ្សែភាគខាងត្បូង រំពឹងថានឹងកើនឡើងបើប្រៀបធៀបជាមួយឆ្នាំមុន។ ប៉ុន្តែដោយពិចារណាលើការបន្តបិទព្រំដែនជាមួយប្រទេសថៃ យើងនៅតែរក្សាជំហរប្រុងប្រយ័ត្នខ្ពស់ចំពោះខ្សែភាគខាងជើង។ ដូចនេះ យើងរំពឹកថា RR នឹងបន្តរក្សាលទ្ធផលចំណូលប្រតិបត្តិការរបស់ខ្លួនក្នុងរយៈពេល ១២ខែខាងមុខនេះ។ វាត្រូវបានគាំទ្រដោយ លទ្ធផលហិរញ្ញវត្ថុប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ របស់ក្រុមហ៊ុន និង កំណើនសេដ្ឋកិច្ចកម្ពុជា ដែលបានព្យាករណ៍ដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ទោះបីជាចំនួនអ្នកដំណើរមានការថយចុះនៅក្នុងឆ្នាំ២០២៥ ក៏ដោយ ការដាក់ឱ្យប្រើប្រាស់នូវកៅអីអង្គុយលំដាប់ប្រណីត ត្រូវបានរំពឹងថានឹងជួយប៉ះប៉ូវដល់ផលប៉ះពាល់នេះ។ យើងរំពឹងថាកំណើនប្រាក់ចំណូលនឹងពឹងផ្អែកចម្បងទៅលើការកើនឡើងនៃបរិមាណទំនិញដែលមានទំហំមិនទាន់គ្រប់គ្រាន់ដើម្បីទទួលបានប្រាក់ចំណេញពីប្រតិបត្តិការ។ ក្រុមហ៊ុនទទួលបានលិខិតលើកលែងការបំពានលើកិច្ចព្រមព្រៀងឥណទានសម្រាប់ខែមិថុនា ឆ្នាំ២០២៥ និង កំពុងតែដាក់លិខិតស្នើសុំការលើកលែងមួយផ្សេងទៀតចំពោះការបំពានកិច្ចព្រមព្រៀងឥណទានសម្រាប់ខែធ្នូ ឆ្នាំ២០២៥។ ការបំពានលើកិច្ចព្រមព្រៀងឥណទាននេះ បូករួមជាមួយនឹងហានិភ័យនៃការបំពានលើកិច្ចព្រមព្រៀងបន្ថែមទៀតនាពេលអនាគតអំឡុងពេលសុពលភាពនៃសញ្ញាបណ្ណ និងភាពមិនច្បាស់លាស់នៃម៉ាក្រូសេដ្ឋកិច្ចគាំទ្រនូវការរក្សាទស្សនៈមិនផ្លាស់ប្តូររបស់យើង ចំពោះលទ្ធភាពសងរបស់ RR។ ដូច្នេះ យើងរក្សាទស្សនវិស័យនៅ «អវិជ្ជមាន» ដដែល។

កត្តាដែលមានឥទ្ធិពលលើបម្រែបម្រួលការវាយតម្លៃ

ក្នុងករណីដែលអាចប្រសើរឡើង ការទទួលបានលិខិតលើកលែងពី GuarantCo ការមិនបំពានកិច្ចព្រមព្រៀងឥណទានបន្ថែម(ក្នុងរយៈពេលឥណប្រតិទាន) ការបង្កើនសកម្មភាពប្រតិបត្តិការ អវត្តមាននៃការរាំងស្ទះម៉ាក្រូសេដ្ឋកិច្ច និងការធ្វើឱ្យប្រសើរឡើងនៃហានិភ័យឥណទាន អាចនាំឱ្យយើងពិនិត្យឡើងវិញនូវការវាយតម្លៃចំណាត់ថ្នាក់ឥណទានក្រុមហ៊ុន និង ទស្សនវិស័យរបស់យើង។

ផ្ទុយទៅវិញ ក្នុងករណីដែលមានការកើនឡើងយ៉ាងគំហុកនៃកម្រិតហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អាចបណ្តាលឱ្យយើងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ឥណទានក្រុមហ៊ុនបាន។ ចំណែកឯ ចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណវិញ ដោយសារតែវាអាស្រ័យទៅនឹងចំណាត់ថ្នាក់ជាសកលរបស់ GuarantCo (AA- ដោយ Fitch Ratings និង A1 ដោយ Moody's Ratings) នោះយើងអាចនឹងពិចារណាលើការបន្ទាបចំណាត់ថ្នាក់ឥណទានសញ្ញាបណ្ណ ប្រសិនបើចំណាត់ថ្នាក់ជាសកលរបស់ GuarantCo ត្រូវបានបន្ទាប។

បញ្ហាដែលត្រូវត្រួតពិនិត្យ

នាពេលខាងមុខ ការទទួលបានលិខិតលើកលែងពី GuarantCo ការបំពានកិច្ចព្រមព្រៀងឥណទានផ្សេងទៀតដែលអាចកើតមាននាពេលអនាគត កំណើនប្រាក់ចំណូលដែលបានរំពឹងទុកពីការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មស្នូល និង ប្រភពចំណូលផ្សេងទៀត ប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសម្បទាន លក្ខខណ្ឌម៉ាក្រូសេដ្ឋកិច្ច ការប្រែប្រួលនៃតម្លៃប្រេងម៉ាស៊ូត និងស្ថានភាពហិរញ្ញវត្ថុរបស់ RR គឺជា ចំណុចសំខាន់ៗទាំងអស់ដែលចាំបាច់ត្រូវតាមដានយ៉ាងយកចិត្តទុកដាក់។

សេចក្តីសង្ខេបអំពី ក្រុមហ៊ុន រ៉ូយ៉ាល់ រេលវ៉ៃ

ទិដ្ឋភាពទូទៅ

សម្រាប់ចក្ខុវិស័យនាពេលអនាគត ADB បានព្យាករណ៍ថាប្រទេសកម្ពុជានឹងមានកំណើនសេដ្ឋកិច្ច ៤.៥% សម្រាប់ឆ្នាំ២០២៦នេះ ស្របជាមួយនឹងគំនិតផ្តួចផ្តើមបន្តបន្ទាប់របស់រាជរដ្ឋាភិបាល ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធដឹកជញ្ជូនតាមផ្លូវរថភ្លើងរបស់ប្រទេសជាតិ រំពឹងថាអាចបង្កើនតម្រូវការសេវាដឹកជញ្ជូនទំនិញនិងអ្នកដំណើររបស់ក្រុមហ៊ុន។ ក្នុងឆ្នាំហិរញ្ញវត្ថុ ២០២៥ ប្រាក់ចំណូលបានពីការដឹកជញ្ជូនទំនិញបានកើនឡើងយ៉ាងខ្លាំង បើទោះបីជាការនាំចូលពីប្រទេសថៃនៅចន្លោះខែមិថុនា និង ខែវិច្ឆិកា មានការធ្លាក់ចុះ ៣៤.៥% ក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ចំណេញសុទ្ធរបស់ RR ត្រូវបានពិនិត្យឃើញថាកាន់តែមានភាពអវិជ្ជមានដោយសារតែ ចំណាយការប្រាក់ខ្ពស់ និងតម្លៃប្រេងម៉ាស៊ូតកើនឡើង ដោយបានដាក់សម្ពាធបន្ថែមទៀតទៅលើប្រាក់ចំណេញពីប្រតិបត្តិការ និងប្រាក់ចំណេញសរុប។ ជាលទ្ធផល យើងរក្សាចំណាត់ថ្នាក់ឥណទានក្រុមហ៊ុននៅ «**khCCC**» ដដែល។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

ការប្រតិបត្តិ

ប្រាក់ចំណូលបានបង្ហាញពីនិន្នាការកើនឡើងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ដោយទទួលបានអត្រាកំណើនប្រចាំឆ្នាំសមាស (CAGR) ១០,២% ចន្លោះឆ្នាំ២០២១ និង ឆ្នាំ ២០២៥។ បើទោះបីជាប្រាក់ចំណូលមានកំណើនប្រចាំឆ្នាំតែ ១,២% សម្រាប់ឆ្នាំ២០២៣ធៀបនឹងឆ្នាំចាស់ក៏ដោយ ក្រុមហ៊ុនសម្រេចបាននូវកំណើនប្រចាំឆ្នាំកាន់តែខ្លាំង ពោលគឺ ៩,១% ក្នុងឆ្នាំ២០២៤ធៀបនឹងឆ្នាំចាស់ និង ២២,៤% ក្នុងឆ្នាំ២០២៥ធៀបនឹងឆ្នាំចាស់។ វាត្រូវបានជំរុញដោយការកើនឡើងនៃចំណូលដឹកជញ្ជូនទំនិញ និងការកើនឡើងតិចតួចនៃចំណូលពីសេវាកម្មតម្លៃបន្ថែមពាក់ព័ន្ធនឹងការដឹកជញ្ជូនតាមរថភ្លើង សម្រាប់ខ្សែភាគខាងត្បូង។ ក្នុងឆ្នាំ២០២៥ បរិមាណដឹកជញ្ជូនទំនិញសរុបបានកើនឡើង ៤៦,៣% ធៀបនឹងឆ្នាំចាស់ ស្របពេលដែលចំនួនអ្នកធ្វើដំណើរតាមរថភ្លើងមានការធ្លាក់ចុះ ១២,៨%។ ប្រាក់ចំណេញពីប្រតិបត្តិការបានកើនឡើងបន្តិចបន្តួចចំនួន ២,៨% បើធៀបទៅនឹងឆ្នាំមុន ខណៈពេលដែលការខាតបង់សុទ្ធត្រូវបានកាត់បន្ថយ ដោយសារចំណាយហិរញ្ញវត្ថុថយចុះ ១,១លានដុល្លារអាមេរិក។

ទម្រង់កម្រិតបំណុលរបស់ក្រុមហ៊ុនបានធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ដោយអនុបាតបំណុលធៀបនឹងមូលធន កើនឡើងដល់ ១៧១,១% ក្នុងឆ្នាំ២០២៤ និង ២១៨,៥% ក្នុងឆ្នាំ២០២៥។ គិតត្រឹមឆ្នាំ២០២៥ អនុបាតលំហូរសាច់ប្រាក់ និង អនុបាតលទ្ធភាពបង់ការប្រាក់របស់ RR ទោះបីជានៅតែមានភាពអវិជ្ជមាន ក៏បង្ហាញឱ្យឃើញថាមានភាពរឹកចម្រើនជាងឆ្នាំមុនៗ។ ការកើនឡើងនេះ បង្ហាញពីការរីកចម្រើននៃលទ្ធផលប្រតិបត្តិការ ទោះបីជាក្រុមហ៊ុននៅតែស្ថិតក្នុងដំណាក់កាលស្តារឡើងវិញក៏ដោយ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh
RAC website

របាយការណ៍ហិរញ្ញវត្ថុសង្ខេប

	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ ដុល្លារអាមេរិក	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២២ ដុល្លារអាមេរិក	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៣ ដុល្លារអាមេរិក	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៤ ដុល្លារអាមេរិក	ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥ ដុល្លារអាមេរិក
របាយការណ៍ចំណេញ/ខាត					
ចំណូល	៩.៣៧២.៦៣៩	១០.២២៩.៧០៧	១០.៣៤៨.០៥១	១១.២៨៦.៦១៤	១៣.៨១៤.៧០៨
ចំណេញដុល	៤៣១.១៣០	(២.០៣០.៩៤៣)	(២.០០១.១៩៣)	(២.៣១៨.៨៤៤)	(៣.៥៤០.៤០៧)
ចំណេញពីប្រតិបត្តិការ	(៥៩០.៦០៥)	(៣.៧៤៧.៩៤៣)	(១.៦៦៤.១១៣)	(៣.៨២០.២១០)	(៣.៧១១.៦៥៤)
ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ	(៧៤៨.៩៧៨)	(៤.១១៨.៥៧១)	(៥.៣៩២.៦៧៨)	(៨.១៥៦.២៧១)	(៦.៩០៦.១០៥)
ប្រាក់ចំណេញប្រចាំឆ្នាំ	**(៧៤៨.៩៧៨)**	**(៤.១១៨.៥៧១)**	**(៥.៣៩២.៦៧៨)**	**(៨.១៥៦.២៧១)**	**(៦.៩០៦.១០៥)**
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ					
ទ្រព្យសកម្ម					
សាច់ប្រាក់ និងសមមូលសាច់ប្រាក់	១២១.៧៦៦	២៣.៩៨១.២៩៧	១៧.៤៨៥.៨២៨	៤.៧២៦.១៧៦	១.៤៥៨.២៥០
សន្និធិ	១២៩.៥៧៦	២១៤.៨៣៥	១៥៤.៦០២	៩៤.៩២៦	១៣៩.១០១
គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ	៩៣២.៥៤៦	២.៣៧០.៧១៨	២.៩១៣.៧៥០	២.៤២៧.២៤៨	១.០៩៧.៧៤៦
ទ្រព្យសកម្មរយៈពេលខ្លីសរុប	**១.១៨៣.៨៨៨**	**២៦.៥៦៦.៨៥០**	**២០.៥៥៤.១៨០**	**៧.២៤៨.៣៥០**	**២.៦៩៥.០៩៧**
ទ្រព្យសម្បត្តិ និងគ្រឿងបរិក្ខារ	៦.២៤៥.០០៤	៧.០០៧.៩៣១	៨.៨៧២.៨១៨	១៧.២៣៤.៧៩៦	១៩.៤២៩.២៤៩
ទ្រព្យសកម្មរយៈពេលវែងសរុប	**៦.៥២១.០២២**	**១១.០៤១.២៣៩**	**១៣.១១៨.៥៤២**	**២៤.០១៧.០៥៥**	**២៦.១២៨.៧០១**
ទ្រព្យសកម្មសរុប	**៧.៧០៤.៩១០**	**៣៧.៦០៨.០៨៩**	**៣៣.៦៧២.៧២២**	**៣១.២៦៥.៤០៥**	**២៨.៨២៣.៧៩៨**
បំណុលនិងមូលធន					
គណនីអ្នកផ្គត់ផ្គង់ និងគណនីត្រូវទូទាត់ផ្សេងៗ	៤.៥៣៨.៨៥៤	៣.៧៤១.០៧៣	២.៧០២.៥០៧	៣.៤៤៧.៤៨២	៤.៦៥៩.០៨៩
ខ្ចីមុលរយៈខ្លី	៨៣៥.១១៤	១.៧៨២.៤០០	៣.៤៣២.៧៨៤	៦.៨០០.៥៧៦	១៣.៩៨៣.៣៩២
មូលបត្របំណុល	០	២៣៣.៧៦៣	២៤.០៩៤.៨១៣	២៤.៩៨៧.៥២៣	២១.៣៣៣.៧០១
បំណុលរយៈពេលខ្លីសរុប	**៥.៤៦៤.៨៨៤**	**៥.៩០៩.៦៣៤**	**៣០.៣៣៤.០២៦**	**៣៥.៤០០.៤០៤**	**៤០.១៨០.២៧២**
ខ្ចីមុលរយៈវែង	៣២៩.៣៦២	៨៥៥.២២៧	១.០៨៧.៣១៧	៨៥៨.២១៨	៦០៧.៤៥៤
មូលបត្របំណុល	០	៣៣.០៥១.២៤៣	៩.៨០៩.៣២៧	៩.៨០៩.៣២៧	៩.៨០៩.៣២៧
បំណុលរយៈពេលវែងសរុប	**៣៩១.១៦៣**	**៣៣.៩៦៨.១៦៣**	**១១.០០១.០៨២**	**១១.៦៨៣.៦៥៨**	**១១.៣៦៨.២៨៨**
បំណុលសរុប	**៥.៨៥៦.០៤៧**	**៣៩.៨៧៧.៧៩៧**	**៤១.៣៣៥.១០៨**	**៤៧.០៨៤.០៦២**	**៥១.៥៤៨.៥៦០**
ដើមទុន	១៣.០២០.៩៣០	១៣.០២០.៩៣០	១៣.០២០.៩៣០	១៣.០២០.៩៣០	១៣.០២០.៩៣០
ខាតបង្គរ	(១១.១៧២.០៦៧)	(១៥.២៩០.៦៣៨)	(២០.៦៨៣.៣១៦)	(២៨.៨៣៩.៥៨៧)	(៣៥.៧៤៥.៦៩២)
មូលធនសរុប	**១.៨៤៨.៨៦៣**	**(២.២៦៩.៧០៨)**	**(៧.៦៦២.៣៨៦)**	**(១៥.៨១៨.៦៥៧)**	**(២២.៧២៤.៧៦២)**
បំណុលនិងមូលធនសរុប	**៧.៧០៤.៩១០**	**៣៧.៦០៨.០៨៩**	**៣៣.៦៧២.៧២២**	**៣១.២៦៥.៤០៥**	**២៨.៨២៣.៧៩៨**
របាយការណ៍លំហូរសាច់ប្រាក់					
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ	១.១៨០.៣៤២	(៥.៨០០.២៨៤)	(៥.៥៤១.៣២៣)	(៥.២៦៩.៩២៨)	(១.០៤៩.៤៦៨)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពវិនិយោគ	(៣៤៨.៦៦១)	(១.៧១៧.៧៩១)	(២.៨៦៧.០៥៧)	(១០.៥០៩.៨៣០)	(៥.០០២.២៤៩)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន	(៨២៥.៣៧៥)	៣១.៥៨៨.១៣៣	១.៨៦៦.៣៧៩	២.៩២៤.០៦៥	២.៧៥៥.៥៨៨
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងឆ្នាំ	**៦.៣០៦**	**២៤.០៧០.០៥៨**	**(៦.៥៤២.០០១)**	**(១២.៨៥៥.៦៩៣)**	**(៣.២៩៦.១២៩)**
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមឆ្នាំ	១១៥.៤៦០	១២១.៧៦៦	២៤.១៩១.៨២៤	១៧.៦៤៩.៨២៣	៤.៧៩៤.១៣០
សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងឆ្នាំ	**១២១.៧៦៦**	**២៤.១៩១.៨២៤**	**១៧.៦៤៩.៨២៣**	**៤.៧៩៤.១៣០**	**១.៤៩៨.០០១**

©អក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតជីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរសព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website

និយមន័យចំណាត់ថ្នាក់ឥណទាន

ចំណាត់ថ្នាក់វាយតម្លៃឥណទាន (ចំណាត់ថ្នាក់ជាតិ)			
ចំណាត់ថ្នាក់ជាតិ	**និយមន័យ**	**ពិន្ទុ**	
khAAA	សមត្ថភាពខ្លាំងណាស់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	១	ហានិភ័យទាបណាស់
khAA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	២	
khA	សមត្ថភាពខ្លាំងក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែពេលខ្លះអាចងាយទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៣	ហានិភ័យទាប
khBBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែមានភាពងាយនឹងទទួលរងការផ្លាស់ប្តូរអវិជ្ជមានក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៤	
khBB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែងាយរងគ្រោះជាងទៅតាមការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៥	ហានិភ័យមធ្យម
khB	សមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ ប៉ុន្តែទំនងជារងផលប៉ះពាល់ដោយការផ្លាស់ប្តូរអវិជ្ជមាននៅក្នុងកាលៈទេសៈ និងបរិយាកាសសេដ្ឋកិច្ច	៦	
khCCC	សមត្ថភាពបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ អាស្រ័យលើលក្ខខណ្ឌអាជីវកម្ម ហិរញ្ញវត្ថុ និងសេដ្ឋកិច្ចអំណោយផល	៧	ហានិភ័យខ្ពស់
khCC	សមត្ថភាពខ្សោយក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៨	
khC	ទំនងជាមិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ	៩	ហានិភ័យខ្ពស់ណាស់
khD	មិនអាចបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ មួយផ្នែក ឬ ទាំងអស់	១០	

កំណត់សម្គាល់៖

ព័ត៌មាន និងទិន្នន័យស្ថិតិនៅទីនេះត្រូវបានទទួលពីប្រភពដែលយើងជឿថាអាចទុកចិត្តបាន។ ព័ត៌មានបែបនេះមិនត្រូវបានផ្ទៀងផ្ទាត់ដោយឯកជ្យទេ ហើយយើងមិនតំណាង ឬការធានាចំពោះភាពត្រឹមត្រូវច្បាស់លាស់ និងភាពពេញលេញរបស់ព័ត៌មានឡើយ។ រាល់មតិ ឬការប៉ាន់ប្រមាណនៅទីនេះឆ្លុះបញ្ចាំងពីការវិនិច្ឆ័យរបស់ក្រុមហ៊ុន អេតធីង អេជេនស៊ី អហ្វ (ខេមបូឌា)ម.ក (ដែលហៅកាត់ថា "RAC") នៅកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយអាចផ្លាស់ប្តូរបានគ្រប់ពេលដោយមិនមានការជូនដំណឹងជាមុន។ រាល់ការដោក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យនៅទីនេះបង្កើតជាការវិនិច្ឆ័យគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ហើយមិនអាចមានការធានាថា លទ្ធផល ឬព្រឹត្តិការណ៍នាពេលអនាគតនឹងមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការដោក់ពិន្ទុ មតិ ការប៉ាន់ប្រមាណ ការព្យាករណ៍ ឬការវាយតម្លៃហានិភ័យណាមួយឡើយ។ ព័ត៌មាននៅក្នុងឯកសារនេះគឺអាចផ្លាស់ប្តូរដោយគ្មានការជូនដំណឹង ភាពត្រឹមត្រូវច្បាស់លាស់របស់វាមិនត្រូវបានធានាទេ វាអាចមិនពេញលេញ ឬបង្រួម ហើយវាប្រហែលជាមិនមែនព័ត៌មានធំ ទាំងអស់ទាក់ទងនឹងក្រុមហ៊ុន (ឬក្រុមហ៊ុនច្រើន) ដែលយោងទៅតាមរបាយការណ៍នេះទេ ហើយ RAC មិនស្ថិតនៅក្រោមកាតព្វកិច្ច ធ្វើបច្ចុប្បន្នភាពព័ត៌មាននៅក្នុងរបាយការណ៍នេះផងដែរ។ ក្នុងវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ RAC និងនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងរបស់ខ្លួនមិនទទួលខុសត្រូវចំពោះការខូចខាត ដោយផ្ទាល់ ឬសំណងណាមួយចំពោះបុគ្គល ឬអង្គភាពណាមួយ រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ដោយការធ្វេសប្រហែសណាមួយនៅក្នុងផ្នែកនៃ ឬបញ្ហាអាសន្នណាមួយនៅក្នុង ឬលើសពីការគ្រប់គ្រងរបស់ RAC ឬនាយក បុគ្គលិក ភ្នាក់ងារ និងអ្នកតំណាងណាមួយរបស់ខ្លួន ដែលកើតឡើងពី ឬពាក់ព័ន្ធនឹងព័ត៌មានដែលមាននៅទីនេះ ឬ ការប្រើប្រាស់ ឬអសមត្ថភាពក្នុងការប្រើប្រាស់ព័ត៌មានបែបនេះ។

©រក្សាសិទ្ធគ្រប់យ៉ាងដោយក្រុមហ៊ុនរេតធីង អេជេនស៊ី អហ្វ (ខេមបូឌា) ម.ក ឆ្នាំ២០២៦
©Copyright 2026, RATING AGENCY OF (CAMBODIA) PLC. All rights reserved.
អាសយដ្ឋាន៖ អគារលេខ២៤៦,មហាវិថីព្រះមុនីវង្ស ភូមិ១០ សង្កាត់បឹងកក់២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address: #246, Preah Monivong Blvd, Village 10, Sangkat Boeung Raing, Khan Daun Penh, Phnom Penh, Kingdom of Cambodia
ទូរស័ព្ទ៖ (៨៥៥)២៣ ៩០២ ៤០៨ សារអេឡិចត្រូនិច៖ info@ratingagencyofcambodia.com.kh
Phone: (+855)23 902 408 Email: info@ratingagencyofcambodia.com.kh

RAC website